USAID
ជំនួយពីពលរដ្ឋអាមេរិក

អង្គការវីនរ៉ក់ អន្តរជាតិ
WINROCK INTERNATIONAL
Putting Ideas to Work



# គម្រោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដំណាក់កាលទី២ (CTIP II)

ចេញផ្សាយលេខ ៥ ខែតុលា - ធ្នូ ឆ្នាំ២០១៤

## ក្មួនក្រមុំដែលរងការរំលោភបំពានផ្លូវភេទ បានរំដោះខ្លួន ចេញពីក្រុមជនល្មើស

នាងយ.ស មានអាយុ២០ឆ្នាំ នាងមានបំណងជួយផ្គត់ផ្គង់ជីវភាពគ្រួសារក្រីក្ររបស់នាង។ ឪពុករបស់នាងបានស្លាប់ចោលនាងជាយូរយារណាស់មកហើយ ចំណែកម្តាយនាងក៏មានជំងឺទៀត ។ នៅក្នុងគ្រួសារ មានតែនាងម្នាក់គត់ដែលអាចរកប្រាក់ចិញ្ចឹមគ្រួសារនាងបាន ។

ថ្ងៃមួយម្តាយមីងនាងបានមករកនាង ហើយលួងលោមនាងឲ្យរៀបការជាមួយបុរសចិនម្នាក់ជាអ្នកមានទ្រព្យសម្បត្តិរស់នៅប្រទេសចិន។ នាងយ.ស មិនធ្លាប់ឮអំពីកូនក្រមុំដែលត្រូវគេជួញដូរទៅប្រទេសចិនទេ ហើយនាងមានក្តីសង្ឃឹមយ៉ាងខ្លាំងនៅពេលដែលមេខ្យល់ប្រាប់នាងថា នាងអាចនឹងផ្ញើប្រាក់ឲ្យគ្រួសាររបស់នាងបាន។ ហេតុនេះ ក្រោយពេលមេខ្យល់រៀបចំធ្វើលិខិតឆ្លងដែន និងទិដ្ឋាការឲ្យនាងរួចរាល់ហើយ នាងបានឡើងយន្តហោះចេញដំណើរជាមួយនារី៣នាក់ផ្សេងទៀតដែលមានក្តីសង្ឃឹម និងផែនការអនាគតដូចរូបនាងដែរ។

នៅពេលនាងទៅដល់ប្រទេសចិនភ្លាម នាងស្រងាកចិត្តយ៉ាងខ្លាំងដោយគេដកហូតលិខិតឆ្លងដែនរបស់នាង ហើយនាងក៏មិនបានស្គាល់លេខទូរស័ព្ទជំនួយបន្ទាន់នៅប្រទេសចិនក៏ដូចជានៅប្រទេសកម្ពុជា។ នាងត្រូវបានគេលក់ពីបុរសម្នាក់ទៅបុរសម្នាក់ទៀត ហើយបង្ខំនាងឲ្យរួមភេទជាមួយបុរសទាំងនោះ។ ភពងងឹតនេះបានកន្លងផុតទៅអស់រយៈពេល៦ខែ។

ដើម្បីរស់រានមានជីវិតបន្តទៀត នាងខិតខំព្យាយាមរត់គេច និងបានទាក់ទងសុំការជួយពីប៉ូលីសចិន។ សំណាងល្អ នាងនៅចាំលេខលិខិតឆ្លងដែនរបស់នាង ហើយប៉ូលីសបានទាក់ទងរកអ្នកបកប្រែភាសាខ្មែរឲ្យនាង។ នាងបានសម្រេចចិត្តធ្វើដំណើរទៅស្ថានទូតកម្ពុជានៅទីក្រុងប៉េកាំង ដើម្បីធ្វើមាតុភូមិនិវត្តន៍មកកាន់ប្រទេសកំណើតវិញ។ នាងមិនបានទទួលជំនួយផ្សេងៗទេ។ ដោយសារគ្មានជម្រើស នាងក៏បានសុំឲ្យគ្រួសាររបស់នាងខ្ចីប្រាក់គេរួចផ្ញើទៅនាងដើម្បីទិញសំបុត្រយន្តហោះត្រឡប់មកផ្ទះវិញ។

នៅពេលមកដល់កម្ពុជាវិញ នាងយ.សមានអារម្មណ៍ខ្មាស់អៀនយ៉ាងខ្លាំងព្រមទាំងបាត់ទំនុកចិត្តទៀតផង។ សំណាងល្អ តាមរយៈការណែនាំពីមិត្តភក្តិរបស់នាង នាងបានរត់ទៅរកអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ (CWCC) ដែលជាដៃគូគម្រោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សដំណាក់កាលទី២ រួចនាងបានទទួលការគាំទ្រផ្នែកចិត្តសាស្ត្រ។ អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិបានផ្តល់របស់របរ និងអាហារចាំបាច់នានា ដូចជា អង្ករ និងថ្នាំសង្កូវជាដើមដល់នាង។

*“ខ្ញុំសូមអរគុណអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ ដែលបានផ្តល់ការគាំទ្រផ្នែកចិត្តសាស្ត្រដល់ខ្ញុំ ធ្វើឲ្យខ្ញុំមានក្តីសង្ឃឹមថ្មី និងរីករាយយ៉ាងខ្លាំងពេលនេះ”*

ក្រោយពេលប៉ាន់ប្រមាណតម្រូវការរបស់នាងរួច អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិបានជួយនាងឲ្យបានចូលរៀនក្នុងវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈកែសម្ផស្ស។ បច្ចុប្បន្ន នាងយ.សកំពុងរៀនកែសម្ផស្សនៅពេលថ្ងៃ និងធ្វើការក្នុងភោជនីយដ្ឋានមួយនៅពេលយប់ដើម្បីរកប្រាក់ចំណូល។ ក្រោយពេលរៀនជំនាញចប់ អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិនឹងជួយនាងក្នុងការរៀបចំផែនការបើកមុខរបរតូចមួយ និងផ្តល់ប្រាក់មួយចំនួនសម្រាប់មុខរបរនោះ ដើម្បីធ្វើយ៉ាងណាឲ្យនាងអាចចាប់ផ្តើមមុខរបរបាន និងមានការងារនឹងនរមួយ។



### សង្ខេបទិន្នន័យនៃគម្រោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដំណាក់កាលទី២ CTIP II ( ២០១១-២០១៥ )

**ចំនួនជនរងគ្រោះដែលបានទទួលសេវាគាំទ្រ៖**

- ៥៩៩នាក់ ជនរងគ្រោះដោយសារការជួញដូរពលកម្ម
- ៥៥នាក់ ជនរងគ្រោះដោយសារការជួញដូរផ្លូវភេទ
- ១៤០នាក់ ជនរងគ្រោះដោយសារការកេងប្រវ័ញ្ចពលកម្ម

**ប្រភេទជំនួយ និងសេវាដែលបានផ្តល់៖**

- ៤៤៧នាក់ ត្រូវបានធ្វើមាតុភូមិនិវត្តន៍
- ៤៩៥នាក់ បានទទួលការប្រឹក្សាផ្នែកផ្លូវចិត្ត
- ៣៩៦នាក់ បានទទួលការប្រឹក្សាផ្នែកច្បាប់
- ៨៩នាក់ ត្រូវបានជួយក្នុងការដាក់ពាក្យបណ្តឹងប្រឆាំងនឹងអ្នកប្រព្រឹត្តិបទល្មើស
- ៤៤នាក់ បានទទួលការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងរបរចិញ្ចឹមជីវិត
- ២០០នាក់ ត្រូវបានធ្វើសមាហរណកម្ម
- ៨៤នាក់ បានទទួលដើមទុនបង្កើតមុខរបរ

**បានធ្វើបច្ចុប្បន្នភាពត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៤*

## បទវិចារណកថា

ចាប់តាំងពីខែកក្កដា មានជនចំណាកស្រុកខ្មែរជាង ៤០០.០០០ នាក់ ដែលគ្មានលិខិតស្នាម ត្រូវគេចុះបញ្ជីនៅប្រទេសថៃតាមរយៈការិយាល័យច្រកចេញចូលតែមួយ។ គេបានប៉ាន់ប្រមាណថា នៅមានជនចំណាកស្រុកប្រហែលជា ៣០០.០០០ នាក់បន្ថែមទៀតដែលធ្វើការនៅទីនោះ និងនៅមានប្រជាពលរដ្ឋខ្មែរជាច្រើនទៀតអាចនឹងធ្វើចំណាកស្រុកក្នុងរយៈពេលប៉ុន្មានខែខាងមុខនេះ។ ពិតប្រាកដណាស់ ប្រទេសថៃនឹងត្រូវការពលករចំណាកស្រុកបន្ថែមទៀតជាពិសេសពលករដែលគ្មានជំនាញសម្រាប់រយៈពេល២ឆ្នាំខាងមុខនេះ ហើយកម្ពុជានៅតែជាប្រទេសបញ្ជូនពលករចំណាកស្រុកដដែល។

នៅកម្ពុជា រាជរដ្ឋាភិបាលបានបង្កើតការិយាល័យច្រកចេញចូលតែមួយចំនួនបួនកន្លែងដើម្បីចេញលិខិតឆ្លងដែន និងលិខិតអនុញ្ញាតឲ្យធ្វើការងារដល់ជនចំណាកស្រុកខ្មែរដែលបានធ្វើការនៅប្រទេសថៃរួច តែទោះជាយ៉ាងនេះក្តី ក៏នៅមានជនចំណាកស្រុកមួយចំនួនទៀតកំពុងតែដាក់ពាក្យសុំលិខិតស្នាមទាំងនេះ។ តើហេតុអ្វីបានជាបញ្ហាបែបនេះនៅតែកើតឡើង? ជនចំណាកស្រុកភាគច្រើនបានត្រឡប់ទៅប្រទេសថៃវិញ បន្ទាប់ពីត្រូវគេនិរទេសមួយចំនួនធំមកកម្ពុជាវិញក្នុងខែមិថុនាកន្លងមកនេះ ហើយនៅក្នុងប្រទេសថៃ ពួកគេទទួលបានប័ណ្ណអនុញ្ញាតធ្វើការងារបណ្តោះអាសន្នជាផ្លូវការរហូតដល់ខែមីនា ឆ្នាំ២០១៥ ។



តើកម្ពុជាត្រូវលើកការិយាល័យច្រកចេញចូលតែមួយទៅប្រទេសថៃ ឬក៏ឲ្យស្ថានទូតខ្មែរប្រចាំក្រុងបាងកកចេញលិខិតឆ្លងដែនឲ្យជនចំណាកស្រុកណាដែលបានចុះបញ្ជីនៅប្រទេសថៃរួចហើយ? តើស្ថានទូតខ្មែរមានលទ្ធភាពក្នុងការផ្តល់លិខិតឆ្លងដែនឲ្យជនចំណាកស្រុកជាង ៤០០.០០០ នាក់ដែរឬទេ?

វាជាការងារបន្ទាន់មួយក្នុងការសម្របសម្រួលជាមួយការិយាល័យច្រកចេញចូលតែមួយនៅក្នុងប្រទេសថៃ ដើម្បីចេញលិខិតឆ្លងដែនឲ្យជនចំណាកស្រុកខ្មែរ និងត្រូវទទួលព័ត៌មានផងដែរអំពីជនចំណាកស្រុកដែលបានចុះបញ្ជីដោយអាជ្ញាធរថៃរួច។

ឥឡូវនេះ ប្រទេសថៃបានប្រកាសថា ខ្លួននឹងចេញប័ណ្ណឆ្លងដែនដែលអនុញ្ញាតឲ្យពលករចំណាកស្រុកអាចធ្វើការនៅតាមតំបន់ជាប់ព្រំដែន និងអាចដាក់ពាក្យសុំការផ្ទៀងផ្ទាត់សញ្ជាតិ។ ទោះជម្រើសថ្មីនេះជាជម្រើសដែលអាចអនុញ្ញាតឲ្យពលករចំណាកស្រុកធ្វើការនៅប្រទេសថៃស្របច្បាប់ក៏ដោយ ក៏វានៅតែជាជម្រើសដ៏ប្រថុយប្រថានមួយសម្រាប់ជនចំណាកស្រុកដែលគ្មានលិខិតឆ្លងដែន និងអត្តសញ្ញាណប័ណ្ណក្នុងការធ្វើចំណាកស្រុកផងដែរ។ កង្វះគោលនយោបាយក្នុងកិច្ចសហការរវាងរាជរដ្ឋាភិបាលទាំងពីរក៏អាចធ្វើឲ្យពលករចំណាកស្រុកមានការយល់ច្រឡំផងដែរ។

ប្រទេសថៃត្រូវការកម្លាំងពលករចំណាកស្រុក ចំណែកឯប្រទេសកម្ពុជាវិញត្រូវផ្តល់ការការពារដល់ពួកគេ ក្នុងការសម្របសម្រួលនូវរាល់កិច្ចខិតខំប្រឹងប្រែងស្វែងរកដំណោះស្រាយពិតប្រាកដ និងដាក់ស្តែងក្នុងការគិតគូរពីផលប្រយោជន៍របស់ពលករ និងក្រុមគ្រួសាររបស់ពួកគេ។

## ព័ត៌មានសំខាន់ៗ ស្តីពីតម្លៃ និងនីតិវិធីណែនាំថ្មីៗ ដើម្បីធ្វើទេសន្តរប្រវេសន៍ការងារនៅថៃ

ដើម្បីទទួលបានភាពស្របច្បាប់សម្រាប់ធ្វើការងារនៅប្រទេសថៃ លោកអ្នកអាចដាក់ពាក្យសុំឯកសារស្របច្បាប់នៅ **ការិយាល័យច្រកចេញចូលតែមួយ**។

នៅកម្ពុជាបច្ចុប្បន្ន មានការិយាល័យច្រកចេញចូលតែមួយ៤កន្លែងគឺនៅ:

១ ច្រកប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ
២ ច្រកព្រំ ខេត្តប៉ៃលិន
៣ ច្រកអូរស្មាច់ ខេត្តឧត្តរមានជ័យ
៤ ច្រកចាំយាម ខេត្តកោះកុង

ដើម្បីទទួលបានឯកសារស្របច្បាប់នេះបាន លោកអ្នកត្រូវ:

➤ បង្ហាញប័ណ្ណសម្គាល់ខ្លួនដែលមិនមែនជាជនជាតិថៃ ឬ/និងកិច្ចសន្យាការងារ ឬ/និងប័ណ្ណបញ្ជាក់អត្តសញ្ញាណ (CI) ឬ/និងឯកសារផ្សេងៗទៀតដែលបង្ហាញថាអ្នកធ្លាប់ធ្វើ ឬអ្នកកំពុងធ្វើការងារនៅប្រទេសថៃ ។
➤ បង់ថ្លៃកញ្ចប់សេវា: ថ្លៃលិខិតឆ្លងដែន៤ដុល្លា ថ្លៃទិដ្ឋាការ ២០ដុល្លា ថ្លៃប័ណ្ណអនុញ្ញាតការងារ១០ដុល្លា ថ្លៃធ្វើប័ណ្ណពលករកម្ពុជាធ្វើការងារក្រៅប្រទេស១០ដុល្លា រួចលោកអ្នករង់ចាំរយៈពេល ២០ថ្ងៃនៃថ្ងៃធ្វើការ។

លោកអ្នកនឹងទទួលបានឯកសារសំខាន់បី:

- ប័ណ្ណពលករកម្ពុជាធ្វើការងារក្រៅប្រទេស
- លិខិតឆ្លងដែន មានទិដ្ឋាការការងារ
- ប័ណ្ណអនុញ្ញាតការងារ

នៅពេលលោកអ្នកមានឯកសារទាំងអស់នេះហើយ លោកអ្នកអាចធ្វើទេសន្តរប្រវេសន៍ការងារ និងធ្វើការងារស្របច្បាប់នៅប្រទេសថៃ ។

លោកអ្នកនឹងទទួលបានការគាំទ្រពីមូលនិធិសន្តិសុខសង្គម ហើយលោកអ្នកក៏មានសិទ្ធិអាចផ្លាស់ប្តូរការងារដោយពន្យល់ពីមូលហេតុនៃការផ្លាស់ប្តូរ។




លោកអ្នកអាចទាក់ទងទីភ្នាក់ងារជ្រើសរើសឯកជនដើម្បីរៀបចំឯកសារស្វែងរកការងារក្រៅប្រទេសសម្រាប់លោកអ្នកបានតែគេតម្រូវឱ្យលោកអ្នកបង់ប្រាក់។ សូមពិនិត្យឱ្យបានច្បាស់លាស់អំពីទីភ្នាក់ងារ

ជ្រើសរើសឯកជន ថាតើគេមានអាជ្ញាប័ណ្ណត្រឹមត្រូវ និងគួរឲ្យទុកចិត្តដែរឬទេ?

បើលោកអ្នកកំពុងធ្វើការនៅប្រទេសថៃ ជាពលករមិនទាន់មានឯកសារស្របច្បាប់ លោកអ្នកក៏អាចចុះបញ្ជីនៅការិយាល័យច្រកចេញចូលតែមួយនៅប្រទេសថៃបានដែរ។

នៅប្រទេសថៃ មានច្រកចេញចូលតែមួយចំនួន៨៣កន្លែងនៅទូទាំង ៧៧ ខេត្ត។ រយៈពេលនៃការចុះបញ្ជីគឺរហូតដល់ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៤ និងឯកសារដែលលោកអ្នកទទួលបាន នឹងមានសុពលភាពរហូតដល់ថ្ងៃទី ៣១ ខែមីនា ឆ្នាំ២០១៥។

ដើម្បីធ្វើឯកសារស្របច្បាប់នេះបាន លោកអ្នកត្រូវបង្ហាញ:

- ➤ កិច្ចសន្យាការងារ ឬ/និងប័ណ្ណអនុញ្ញាតការងារ ឬ/និងប័ណ្ណសម្គាល់ខ្លួនមិនមែនជាជនជាតិថៃ
- ➤ ត្រូវពិនិត្យឈាម និងវិភាគទឹកនោម ។ ការពិនិត្យ និងវិភាគទឹកនោម គឺដើម្បីរកសារធាតុញៀនមេតំហ្វេតាមីន មានផ្ទៃពោះ និងមានជម្ងឺកាមរោគ ។
- ➤ ថ្លៃសេវាចុះបញ្ជី: ១៣០៥បាត (សម្រាប់អ្នករស់នៅក្នុងបន្ទុកដែលកំពុងរស់នៅប្រទេសថៃថ្លៃ១០៨០បាតបន្ថែមទៀត)

លោកអ្នកនឹងទទួលបាន:

- ➤ ប័ណ្ណអនុញ្ញាតការងារបណ្តោះអាសន្ន (សុពលភាព៦០ថ្ងៃ) ហើយប័ណ្ណនេះនឹងពន្យាដោយស្វ័យប្រវត្តិរហូតដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៥ (មិនចាំបាច់បង់ប្រាក់បន្ថែម ឬត្រូវត្រឡប់ទៅកាន់ច្រកចេញចូលតែមួយម្តងទៀតឡើយសម្រាប់ការពន្យានេះ)
- ➤ ធានារ៉ាប់រងសុខភាពមានរយៈពេល៣ខែ (ត្រូវបង់ប្រាក់បន្ថែមសម្រាប់ការពន្យា)
- ➤ ប័ណ្ណសម្គាល់ខ្លួន

ទទួលបានឯកសារទាំងអស់នេះ លោកអ្នកអាចធ្វើការងារស្របច្បាប់នៅប្រទេសថៃបានរហូតដល់ ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៥ប៉ុណ្ណោះ ។ ក្នុងអំឡុងពេលនេះ លោកអ្នកនឹងត្រូវចុះឈ្មោះសម្រាប់ដំណើរការផ្ទៀងផ្ទាត់សញ្ជាតិដើម្បីទទួលបានលិខិតឆ្លងដែន និងប័ណ្ណអនុញ្ញាតការងារនៅថៃ។ ប្រសិនបើលោកអ្នកវិលត្រឡប់មកកម្ពុជាវិញ ដោយយកឯកសារទាំងអស់នោះមកជាមួយ លោកអ្នកអាចទៅកាន់ច្រកចេញចូលតែមួយនៅកម្ពុជាដើម្បីធ្វើលិខិតឆ្លងដែន ដោយបង្ហាញឯកសារនៃការចុះបញ្ជីនៅប្រទេសថៃសម្រាប់ការធ្វើការងារបណ្តោះអាសន្នរបស់អ្នកដល់មន្ត្រីច្រកចេញចូលតែមួយ។

បទប្បញ្ញត្តិទាំងអស់នេះអាចនឹងផ្លាស់ប្តូរនៅពេលខាងមុខ។ ក្នុងករណីមានការផ្លាស់ប្តូរ គម្រោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សដំណាក់កាលទី២ នឹងជូនដំណឹងនៃការផ្លាស់ប្តូរបទប្បញ្ញត្តិថ្មីនោះ។

## កម្មវិធីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដំណាក់កាលទី២ ជួយយុវជនក្នុងការត្រៀមខ្លួនសម្រាប់សមាហរណកម្មអាស៊ាន ២០១៥



រិន រ៉ាល់ មានអាយុ១៨ឆ្នាំ ជាសមាជិកបណ្តាញយុវជនស្ម័គ្រចិត្តសហគមន៍នៃសមាគមយុវជនខ្មែរ (KYA) ដែលជាដៃគូរបស់កម្មវិធីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សដំណាក់កាលទី២។ ថ្មីៗនេះ គាត់បានចូលរួមក្នុងសិក្ខាសាលាដែលរៀបចំឡើងដោយ KYA ស្តីពី "យុវជន និងចំណាកស្រុក" ឱកាស និង ការប្រឈម" ហើយគាត់បានចែករំលែកព័តមានដែលទទួលបានពីសិក្ខាសាលាដូចខាងក្រោម៖

«ខ្ញុំគិតថា អ្នកចូលរួមទាំងអស់ទទួលបានចំណេះដឹង និងបទពិសោធន៍ជាច្រើនពីការបកស្រាយដោយតំណាងអង្គការសង្គមស៊ីវិល សាធារណៈជន និងវិស័យឯកជន។ ខ្ញុំយល់ឃើញថា ជាការប្រសើរមួយ បើមានកិច្ចសហប្រតិបត្តិការល្អពីគ្រប់ស្ថាប័នទាំងអស់ ជាពិសេសក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងអប់រំ យុវជន និងកីឡា ក្នុងការបង្កើនឱកាសការងារឲ្យបានច្រើន និងការកាត់បន្ថយការធ្វើចំណាកស្រុកដោយប្រថុយប្រថាន។ ខ្ញុំមានចំណាប់អារម្មណ៍ទៅលើរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលលោកបានលើកឡើងអំពីផែនការរបស់រដ្ឋាភិបាលផ្តោតលើចំណាកស្រុករបស់យុវជន សមាហរណកម្មអាស៊ាន និងលើកទឹកចិត្តយុវជនឲ្យពិចារណាលើឱកាសការងារក្នុងប្រទេស និងវគ្គបណ្តុះបណ្តាលជំនាញខ្លីៗ។ ហើយខ្ញុំក៏ចាប់អារម្មណ៍ផងដែរ ទៅលើវាគ្មិនដែលបានចែករំលែកការយល់ដឹងអំពីការងារនៅក្រៅប្រទេសផងដែរ។ ក្នុងសិក្ខាសាលានេះ ក៏មានអតីតជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងពលករចំណាកស្រុកដែលទទួលបានជោគជ័យក្នុងពេលធ្វើការងារនៅប្រទេសកូរ៉េ ចែករំលែកបទពិសោធន៍របស់ពួកគាត់ផងដែរ។ ការចែករំលែកទាំងនេះបានជួយឲ្យអ្នកចូលរួមបានយល់អំពីការប្រឈម និងភាពជោគជ័យនៃការធ្វើចំណាកស្រុក»។

ជាចុងក្រោយ សិក្ខាសាលានេះពិតជាផ្តល់នូវសារៈសំខាន់ណាស់ក្នុងការត្រៀមខ្លួនសម្រាប់សមាហរណកម្មអាស៊ាន២០១៥ខាងមុខនេះ។ «ខ្ញុំរីករាយសម្រាប់ប្រទេសកម្ពុជា ប៉ុន្តែខ្ញុំក៏មានការព្រួយបារម្ភចំពោះយុវជនដែលខ្វះនូវជំនាញ និងចំណេះដឹង។ ខ្ញុំនឹងព្យាយាមសិក្សាឲ្យកាន់តែខ្លាំងពីព្រោះនៅឆ្នាំ ២០១៥ លំហូរនៃការធ្វើចំណាកស្រុកនឹងកាន់តែកើនឡើង។ ដូចនេះពលករត្រូវរៀបចំ និងត្រៀមខ្លួនឲ្យបានល្អមុននឹងធ្វើចំណាកស្រុក។ ទាំងនេះពិតជាមានសារៈសំខាន់ណាស់ក្នុងការលើកកម្ពស់ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព។ ជាមួយគ្នាដែរ កម្មវិធីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក៏បានបង្ហាញអំពីការប្រើប្រាស់សារឆ្លើយតបជាសម្លេងស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ព្រមទាំងបង្ហាញអំពីនីតិវិធីថ្មីសម្រាប់ធ្វើទេសន្តរប្រវេសន៍ការងារនៅប្រទេសថៃ។

ខ្ញុំសង្ឃឹមថា អ្នកចូលរួមទាំងអស់នឹងផ្សព្វផ្សាយបន្តនូវអ្វីដែលពួកគេទទួលបានពីសិក្ខាសាលានេះ»។

## សូមអរគុណដល់អ្នករត់ម៉ូតូឌុបទាំងឡាយដែលបានទទួលការបណ្តុះបណ្តាលពីគម្រោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សដំណាក់ការទី២ ដែលបានជួយធ្វើឲ្យចំណាកស្រុកមានសុវត្ថិភាព

ខេត្តកោះកុង និងខេត្តត្រាតត្រូវគេស្គាល់ថា ជាខេត្តជាប់ព្រំដែនហើយការត្រួតពិនិត្យព្រំដែននៅមានកម្រិត។ បច្ចុប្បន្នការងារនេះវាទាមទារឲ្យមានការសម្របសម្រួលគ្នាឲ្យកាន់តែប្រសើរឡើងរវាងប្រទេសថៃ និងប្រទេសកម្ពុជា ក្នុងន័យនៃការធ្វើមាតុភូមិនិវត្តន៍របស់ពលករខ្មែរដែលធ្វើចំណាកស្រុក។ ជាទូទៅ គេចាត់ទុកថាអ្នកដែលគេបញ្ជូនត្រឡប់ទាំងនោះជាអ្នកធ្វើចំណាកស្រុកខុសច្បាប់ បើទោះជាក្នុងនោះមានអ្នកចំណាកស្រុកជាច្រើនជាជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងការ កេងប្រវ័ញ្ចក៏ដោយ។

នៅពេលដែលពួកគេត្រូវធ្វើមាតុភូមិនិវត្តន៍ មិនមានប្រព័ន្ធត្រួតពិនិត្យនិងតាមដានឲ្យមានប្រសិទ្ធភាពក្នុងការធ្វើយ៉ាងណាឲ្យបានដឹងថា ពួកគេបានត្រឡប់ទៅសហគមន៍របស់ពួកគេដោយជោគជ័យ និងទទួលបាននូវសេវាសមាហរណកម្មសមស្របនោះទេ។

អង្គការដៃគូរបស់គម្រោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សដំណាក់កាលទី២ មណ្ឌលថែទាំសុខភាពកុមារហៅកាត់ថា HCC បានបង្កើតបណ្តាញអ្នករត់ម៉ូតូឌុបតាមខេត្ត ហើយអ្នកម៉ូតូឌុបទាំងនោះបានទទួលការបណ្តុះបណ្តាលទៀងទាត់ពីការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងចេះពីរបៀបសហការជាមួយអង្គការក្រៅរដ្ឋាភិបាលក្នុងការបញ្ជូនជនដែលអាចជាជនរងគ្រោះដើម្បីទទួលបាននូវសេវាគាំទ្រនានា។ អ្នករត់ម៉ូតូឌុបក៏ធ្វើការផ្សព្វផ្សាយនូវព័ត៌មានអំពីការធ្វើចំណាកស្រុកដោយសុវត្ថិភាពដល់អ្នកធ្វើចំណាកស្រុក និងសហគមន៍ហើយប្រាប់ពីប្រភេទសេវាដែលអ្នកធ្វើចំណាកស្រុកអាចការពារខ្លួន និងអាចទាមទារសិទ្ធិ និងយុត្តិធម៌បានផងដែរ។

អ្នករត់ម៉ូតូឌុបអាចជាអ្នកដើរតួយ៉ាងសំខាន់ក្នុងការជួយអ្នកធ្វើចំណាកស្រុក ដោយសារតែពួកគេមានវប្បធម៌ និងភាសាដូចគ្នា ជាពិសេសអ្នកធ្វើចំណាកស្រុកផ្សេងទៀតងាយនឹងជឿទុកចិត្តពួកគេ។ ជួនកាល ពួកគេថែមទាំងអាចជួយធ្វើជាអ្នកបកប្រែភាសាក្នុងករណីនៃការចោទប្រកាន់ជនសង្ស័យតាមរយៈការស្វែងរកការពិត និងជួយដល់ដំណើរការនៃការស៊ើបអង្កេតទៀតផង។

ដោយសារតែមានការគាំទ្រពីគម្រោងប្រយុទ្ធប្រឆាំងការជួញដូរមនុស្សដំណាក់កាលទី២នេះ បណ្តាញអ្នករត់ម៉ូតូឌុប បានជួយឲ្យយើងអាចបំពេញទម្រង់កំណត់រហ័សនៃករណីជួញដូរបានចំនួន ៥៣ ទម្រង់ នៅតាមព្រំដែនគិតពីខែធ្នូ ឆ្នាំ២០១៣ ដល់ខែកញ្ញា ឆ្នាំ២០១៤។ ក្នុងចំណោមជនចំណាកស្រុកទាំងនោះ ជនចំណាកស្រុកចំនួន ១១ នាក់ ត្រូវរកឃើញថាជាជនរងគ្រោះដោយអំពើជួញដូរមនុស្ស ៧ នាក់ ជាជនរងគ្រោះដោយការកេងប្រវ័ញ្ចកម្លាំងពលកម្ម និង ៣៥ នាក់ផ្សេងទៀត ជាជនចំណាកស្រុកខុសច្បាប់ ដែលងាយនឹងរងគ្រោះដោយអំពើជួញដូរមនុស្ស។ អង្គការ HCC បានផ្តល់នូវសេវាគាំទ្រ និងបានជួយតម្រង់ទិសដល់ជនចំណាកស្រុកខុសច្បាប់ អំពីហានិភ័យដែលអាចនឹងកើតឡើងដោយសារអំពើជួញដូរមនុស្ស និងប្រាប់នូវវិធីជាច្រើនក្នុងការធ្វើចំណាកស្រុកដោយសុវត្ថិភាព។

អរគុណចំពោះការខិតខំប្រឹងប្រែងរបស់អស់លោកអ្នក!

លេខទូរស័ព្ទទំនាក់ទំនងពត៌មានស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព **095 975 804**

ចំពោះអតិថិជនរបស់ក្រុមហ៊ុនសែលកាត (Cellcard)
លោកអ្នកអាចទូរស័ព្ទចូលដោយមិនគិតថ្លៃសេវារហូតដល់ថ្ងៃទី ១០ ខែកក្កដា ឆ្នាំ២០១៥

ប្រសិនបើអ្នកបានជួបទះអំពើជួញដូរមនុស្ស ឬ អ្នករងគ្រោះដោយសារអំពើជួញដូរមនុស្ស អ្នកអាចស្វែងរកជំនួយតាមរយៈអស័យដ្ឋាន និងលេខទំនាក់ទំនងដូចខាងក្រោម៖

### ក្នុងប្រទេសកម្ពុជា

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន
០២៣ ៩៩ ៧៩ ១៩ / ១២ ៨៨

| | | |
|---|---|---|
| ការិយាល័យនគរបាលប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៅតាមបណ្តារាជធានី -ខេត្ត | ភ្នំពេញ | : ០១៧ ២៧៦ ២២២ |
| | សៀមរាប | : ០១៧ ២៥៨ ២២២ |
| | បាត់ដំបង | : ០១៧ ២៣៦ ២២២ |
| | កំពង់ធំ | : ០១៧ ២៥៤ ២២២ |
| | បន្ទាយមានជ័យ | : ០១៧ ២៦០ ២២២ |
| | កំពង់ចាម | : ០១៧ ៣២៦ ២២២ |
| | ក្រុងព្រះសីហនុ | : ០១៧ ២៥៩ ២២២ |

### លេខទំនាក់ទំនងអង្គការនៅកម្ពុជា

អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ
០៩៨ ៣៦០ ០៤៩ (ប៉ោយប៉ែត) ,០៨៨ ៦៩៥ ៤១៧៨ (សៀមរាប)
អង្គការជំនួយផ្លូវច្បាប់ដល់កុមារនិងស្ត្រី
០៧៧ ៤៥៥ ៥១៦
អង្គការមជ្ឈមណ្ឌលកម្ពុជាដើម្បីការពារសិទ្ធិកុមារ
០១២ ៩១៣ ១៣៨

### លេខទំនាក់ទំនងនៅប្រទេសចិន

ស្ថានទូតកម្ពុជា នៅទីក្រុងប៉េកាំង
+៨៦ ១៨ ៨០១៤ ០៧ ៨៦៥

ស្ថានកុងស៊ូលកម្ពុជានៅក្រុងសៀងហៃ
+៨៦ ១៥ ៦០ ១៧ ១៨ ៧៧៧
+៨៦ ១៨ ៥០ ១៦ ៤៣ ៥៣៧

### លេខទំនាក់ទំនងនៅប្រទេសថៃ

ស្ថានទូតកម្ពុជា នៅប្រទេសថៃ
+៦៦ ២៩ ៥៧៥ ៨៥១

អង្គការ LPN
+៦៦ ៣៤ ៤៣៤ ២៦៧

អង្គការស័ម្ពន្ធសកលប្រឆាំងអំពើជួញដូរស្ត្រី
+៦៦ ២៨ ៦៤១ ៤២៧

### លេខទំនាក់ទំនងនៅប្រទេសម៉ាឡេស៊ី

ស្ថានទូតកម្ពុជា នៅប្រទេសម៉ាឡេស៊ី
+៦០ ៣៤ ២៥៧ ១១៥០
+៦០ ៣៤ ២៥៧ ៣៧១១

អង្គការទីណាហ្គានីតា
+៦០ ៣៧ ៧៧០ ៣៦៩១

### លេខទំនាក់ទំនងនៅប្រទេសសិង្ហបូរី

ក្រសួងការងារនៅប្រទេសិង្ហបូរី
+៦៥ ៦៤ ៣៨៥ ១២២ (សម្រាប់សំណួរទូទៅ)
+៦៥ ៦៥ ៣៨៦ ៩៣០ (សម្រាប់គុណភាពសេវា)
ភ្នាក់ងារពឹងពាក់សម្រាប់អ្នកបម្រើដែលស្នាក់ការនៅបណ្តោះអាសន្ន
+៦៥ ៦២ ៤៧៧ ០០១
អង្គការមនុស្សធម៌សម្រាប់សេដ្ឋកិច្ចនៃការធ្វើទេសន្តរប្រវេសន៍ HOME:
លេខទំនាក់ទំនងផ្តល់ជំនួយ២៤ម៉ោងសម្រាប់ពលករស្ត្រី
និងបុរសជនជាតិបរទេស
+៦៥ ៦៣ ៤១៥ ៥២៥ (សម្រាប់ស្ត្រី)
+៦៥ ៦៣ ៤១៥ ៥៣៥ (សម្រាប់បុរស)

អង្គការវីនរ៉ក់អន្តរជាតិ ជាអង្គការមិនរកប្រាក់ចំណេញ ដែលធ្វើការជាមួយប្រជាជននៅសហរដ្ឋអាមេរិក និងទូទាំងពិភពលោកដើម្បីជួយដល់ជនក្រីក្រ បង្កើនឱកាសរកប្រាក់ចំណូល និងថែរក្សាធនធានធម្មជាតិឲ្យបានគង់វង្ស។

ការិយាល័យអង្គការវីនរ៉ក់នៅប្រទេសកម្ពុជា
មជ្ឈមណ្ឌលភ្នំពេញ អគារ អេហ្វ, បន្ទប់លេខ ៧៨៧, មហាវិថី សុធារស, រាជធានីភ្នំពេញ.
ទូរស័ព្ទ +៨៥៥-២៣ ២១២ ៣៣៣៤ / ៦ ទូរសារ +៨៥៥-២៣ ២១២ ៣៣
Email: cambodiaadmin@field.winrock.org. www.winrock.org